**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៩
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០១
<u>សាលដីកា</u>
លេខ:៤០
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណ: នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក .............. ជាចៅក្រមរបាយការណ៍
៥-លោក .............. ជាចៅក្រម
៦-លោក .............. ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ............... ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

-លោក ...............

<u>តំណាងមហាអយ្យការ</u>

-លោក ...............ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៩៨(ធ) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះមអ(ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីសំនៅសព្វថ្ងៃភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះម៉ៅ ម៉ាង (ស្លាប់) ម្តាយឈ្មោះ នង គុំ (ស្លាប់) មានកូន០៣នាក់ ។

-ចុងចម្លើយឈ្មោះមរ(ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះម៉ៅ ម៉ាង (ស្លាប់) ម្តាយឈ្មោះដួង ស៊ីម (ស្លាប់) ប្តីឈ្មោះ មាន ខន មានកូន៧នាក់ ។

<u>**កម្មវត្ថុបណ្តឹង**</u> : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០របស់ឈ្មោះម៉ាង រូ ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ៩៨(ធ)ចុះថ្ងៃទី០២ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់ឈ្មោះ មរអប្តឹងទាមទារដីលំនៅដ្ឋាន ទំហំ ២០មគុណ២០ម ពីឈ្មោះ មរដោយសំអាងហេតុថា ដីនេះរដ្ឋអំណាចបានចែកឱ្យខ្លួនតាំងពីឆ្នាំ ១៩៧៩ ហើយត្រូវឈ្មោះ ម៉ាង រុ ដណ្តើមកាន់កាប់កាលពីឆ្នាំ១៩៩០ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១៣(ក) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់ តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ

១-ទទួលបណ្តឹងរបស់ដើមចោទឈ្មោះមរអចុះថ្ងៃទី១០ខែវិច្ឆិកា ឆ្នាំ១៩៩៥ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ប្រគល់ដីទំនាស់ដែលមានទីតាំងស្ថិតនៅចំណុចភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានទំហំ២០,៣០មគុណ១៨ម មានព្រំប្រទល់ :
ខាងជើងទល់នឹងផ្លូវ,ខាងត្បូងទល់នឹង ប៊ី សុខ,ខាងកើតទល់នឹងផ្លូវ,ខាងលិចទល់នឹងដីទំនាស់ មរ ឱ្យទៅឈ្មោះ មរអកាន់កាប់ប្រើប្រាស់ជាកម្មសិទ្ធិ ។

៣-បង្គាប់ឱ្យឈ្មោះ បង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ដែលដើមចោទបានបង់រួចហើយៗឲ្យឈ្មោះនេះសងទៅដើមចោទវិញ ។

៤-បង្គាប់ឱ្យឈ្មោះ មរបង់ពន្ធសមាមាត្រចំនួន៥០០០រៀល ស្មើនឹង១% លើ តម្លៃដីទំនាស់ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះ ម៉ាង ប្តឹងមិនសុខចិត្ត និង សាលក្រមរដ្ឋប្បវេណីលេខ១៣(ក) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ២៩៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះមរទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះមអទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៣(ក) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្តាល ចោលជាអសារបង់។

៤-ប្រគល់ដីទំនាស់ទំហំ២០,៣០មគុណ១៨ម មានទីតាំងស្ថិតនៅចំណុចភូមិស្រុកធំ ឃុំជើងកើបស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ :

ខាងជើងទល់នឹងផ្លូវ,ខាងត្បូងទល់នឹងដី ប៊ុ សុខ,ខាងកើតទល់នឹងផ្លូវ,ខាងលិចទល់នឹងដីទំនាស់ម៉ាង រុន មរឱ្យទៅឈ្មោះម៉ោង រូ កាន់កាប់ ជាកម្មសិទ្ធិតទៅ ។ ប៉ុន្តែបង្គាប់ឱ្យឈ្មោះ មរប្រគល់ប្រាក់ថ្លៃផ្ទះទៅឱ្យឈ្មោះ មអចំនួន៤០០.០០០រៀល(បួនសែនរៀល) វិញ ។

៥-សម្រេចកាត់យកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធភ្លើង២.៥៥០រៀល ចំណាយ លើការប្រគល់ដីកាកោះ៥.០០០រៀល និងអាជ្ញាធរតុលាការ៥.០០០រៀល ។ កាលបើហួសកំណត់ប្តឹងសាទុក្ខហើយបង្គាប់ឱ្យឈ្មោះមអសងប្រាក់១៣.០០០រៀល នេះទៅឱ្យឈ្មោះ មរវិញ ។ បង្គាប់ឱ្យឈ្មោះ មអបង់ពន្ធសមាមាត្រ១% នៃតម្លៃដីទំនាស់ និងឱ្យឈ្មោះ មរបង់ពន្ធសមាមាត្រ១% លើតម្លៃប្រាក់៤០០.០០០រៀល ។ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីសម្រេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ១៩៦ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ របស់ឈ្មោះមអប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៩៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៧របស់សលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៩ ចុះថ្ងៃទី២២ខែមករា ឆ្នាំ១៩៩៨ របស់តុលាការ កំពូលដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ១៩៦ចុះថ្ងៃទី១០ ខែមិថុនាឆ្នាំ១៩៩៧ របស់អ្នកស្រី មអទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៩៥ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៣០ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលអ្នកស្រីមអបានបង់រួច ហើយគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រី មរសងប្រាក់ចំនួន១៩.០០០រៀល នេះទៅឱ្យអ្នកស្រី មអវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ។

- បានឃើញ សាលដីការដ្ឋប្បវេណីលេខ៩៨ (ធ)ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសម្រេច ដូចតទៅៈ

១-ទទួលរឿងក្ដីលេខ២៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មី ដោយអំណាចសាលដីកាលេខ១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

២-តម្កល់សាលក្រមលេខ១៣(ក)ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការ ខេត្តកណ្ដាល ទុកជាបានការទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ប្រាក់នេះ ចំណាយលើ ពន្ធហ្វឹង និងពន្ធចុះបញ្ជីក្ដីចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០រៀលនិងលើអាជ្ញាធរតុលាការ៥.០០០រៀលបូកសរុប១៣.០០០រៀល។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្ដឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលើកទី២លេខ៤៣២ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០របស់ឈ្មោះមរ ប្ដឹងមិនសុខចិត្តនិងសាលដីកាលេខ៩៨ (ធ)ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចសម្រេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ មរ។

បានឃើញ សារណាតប ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ របស់ឈ្មោះ មអ។

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការថាៈ រឿងនេះជារឿងវិវាទដីធ្លី សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

- បានស្ដាប់ចម្លើយអ្នកស្រី មរ(ម្ចាស់បណ្ដឹងសាទុក្ខ) នៅពេលសវនាការថា ដីទំនាស់នេះ ភូមិ ឃុំ ចែកឱ្យខ្លួន ខ្លួនមានពាក្យសុំកាន់កាប់ គឺភូមិ-ឃុំប្រគល់ឱ្យខ្លួន ។ ឈ្មោះ ម៉ោងព្រឹង ជាប្ដីរបស់ឈ្មោះ មអ រត់គេចពីទាហានមិនបានមករស់នៅលើផ្ទះនេះទេ ។

- បានស្តាប់ចម្លើយអ្នកស្រី មអ(ចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា ដើរនេះជាដីរបស់ខ្លួនពិតប្រាកដ ពេលដែលខ្លួនទៅរកស៊ីនៅភ្នំពេញខ្លួនទុកផ្ទះ និងដីឲ្យម្តាយក្មេក ឪពុកក្មេកថែឲ្យ ។ ពេលដែលឈ្មោះមររុះរើផ្ទះខ្លួនបានឃាត់ដែរ តែគាត់មិនស្តាប់នៅតែរុះ ។
មាំង រូ មានដីដោយខ្លួន មួយឡូត៍មានទទឹង២០ម តែគាត់នៅតែរំលោភយកដីរបស់ខ្លួនទៀត ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៤៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីម៉ា រូ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលចុងចម្លើយលើករឿងនៅពេលសវនាការនេះ ក៏ដូចជានៅក្នុងសារណាចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ របស់អ្នកស្រីថា ដី និងផ្ទះទំនាស់នេះរដ្ឋអំណាចបានបែងចែកឱ្យអ្នកស្រីនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា អ្នកស្រីបានឆ្លើយទទួលស្គាល់ថា នៅឆ្នាំ១៩៧៩-១៩៨២ ដើមចោទពិតជាបានមករស់នៅ និងសង់លំនៅដ្ឋានលើដីទំនាស់ប្រាកដមែន ។
ដូច្នេះដើមចោទមានសិទ្ធិលើដី និងផ្ទះទំនាស់នេះតាមមាត្រា២ នៃអនុក្រឹត្យលេខ២៥ អនក្រចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ហើយ ។ ម្យ៉ាងទៀតពុំមានភស្តុតាងណាបញ្ជាក់ថា រដ្ឋអំណាចប្រគល់ដី និងផ្ទះឱ្យអ្នកស្រីទេ ពីព្រោះរដ្ឋអំណាចបានចែកឱ្យអ្នកស្រីនូវដីមួយឡូតិ៍នៅជិតដីទំនាស់នេះរួចហើយ។

- យល់ឃើញថាសាលាឧទ្ធរណ៍ពុំបានសម្រេច អំពីសំណងខូចខាតផ្ទះដែលចុងចម្លើយរុះរើចេញទេ ប៉ុន្តែដើមចោទពុំបានសាទុក្ខពីសាលដីកានេះ ដូច្នេះតុលាការកំពូលពុំមានសមត្ថកិច្ចសម្រេចបានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៨ (ធ) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេមក្តី ចំពោះមុខគូក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ៤៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រីមរទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាវដ្ឋប្បវេណីលេខ៩៨(ធ) ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រីមរសេងប្រាក់ចំនួន១៩.០០០រៀលនេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើតម្លៃជាក់ស្តែងនៃដីទំនាស់ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ។